ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ [illegible].០២៤.០៦៦.[illegible]

ថ្ងៃចន្ទ ១២កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៤

សេចក្តីប្រកាសព័ត៌មាន
ស្តីពី
ពិធីសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការគម្រោងទូទាត់ឆ្លងដែនតាមឃ្យូអរកូត (QR Code) រវាងធនាគារជាតិនៃកម្ពុជា និងក្រុមហ៊ុន Ant International តាមរយៈប្រព័ន្ធបាគង និងកម្មវិធី Alipay+

នាថ្ងៃចន្ទ ១២កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៤ ធនាគារជាតិនៃកម្ពុជា និងក្រុមហ៊ុន Ant International បានប្រកាសដាក់ឱ្យដំណើរការជាផ្លូវការគម្រោងទូទាត់ឆ្លងដែនតាមឃ្យូអរកូត (QR Code) រវាងប្រព័ន្ធទូទាត់បាគងរបស់ធនាគារជាតិនៃកម្ពុជា និងបណ្តាញទូទាត់ពិភពលោក Alipay+ របស់ក្រុមហ៊ុន Ant International នៅសណ្ឋាគារ សូហ្វីតែល ភ្នំពេញ ភូគីត្រា (Sofitel Phnom Penh Phokeethra)។

គំនិតផ្តួចផ្តើមនេះ នឹងផ្តល់លទ្ធភាពដល់អ្នកប្រើប្រាស់ដែលជាដៃគូរបស់ Alipay+ អាចប្រើប្រាស់កម្មវិធីទូទាត់អន្តរជាតិជាង ៩ រួមមាន Alipay (ចិនដីគោក), Touch'n Go eWallet (ម៉ាឡេស៊ី), GCash (ហ្វីលីពីន), Kakao Pay, Toss Pay (កូរ៉េខាងត្បូង), OCBC និង Changi Pay (សិង្ហបុរី) និងកម្មវិធីទូទាត់ផ្សេងទៀត ដើម្បីធ្វើការទូទាត់ដល់ពាណិជ្ជករជាង ៣.៣ លានទីតាំងក្នុងប្រទេសកម្ពុជា ប្រកបដោយភាពងាយស្រួល តាមរយៈការស្កេនខេអេចឃ្យូអរកូត (KHQR Code)។ ការណ៍នេះ នឹងជួយសម្រួលដល់អាជីវករនៅប្រទេសកម្ពុជាដែលមានគណនីជាប្រាក់រៀល ក្នុងការទទួលការទូទាត់ពីអតិថិជនរបស់ Alipay+។

ពិធីប្រកាសដាក់ឱ្យដំណើរការជាផ្លូវការគម្រោងទូទាត់ឆ្លងដែនតាមឃ្យូអរកូតនេះ បានប្រព្រឹត្តិទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា និងតំណាងក្រុមហ៊ុន Ant International ព្រមទាំងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

កិច្ចសហប្រតិបត្តិការទូទាត់ឆ្លងដែននេះ ជាសមិទ្ធផលថ្មីមួយទៀតនៃចក្ខុវិស័យពង្រីកវិសាលភាពប្រតិបត្តិការទូទាត់ឆ្លងដែនតាមខេអេចឃ្យូអរកូតរបស់ប្រព័ន្ធបាគង បន្ទាប់ពីធនាគារជាតិនៃកម្ពុជា និងក្រុមហ៊ុន Ant International បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ ស្តីពី "កិច្ចសហប្រតិបត្តិការទូទាត់ឆ្លងដែនតាមឃ្យូអរកូត" កាលពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្នុងពិព័រណ៍បច្ចេកវិទ្យាហិរញ្ញវត្ថុសិង្ហបុរីឆ្នាំ២០២៣ នៅប្រទេសសិង្ហបុរី។

សមិទ្ធផលថ្មីនេះ បានឆ្លុះបញ្ចាំងអំពីការលើកកម្ពស់ការទូទាត់ឆ្លងដែន ប្រកបដោយប្រសិទ្ធភាព សុវត្ថិភាពដោយប្រើប្រាស់រូបិយវត្ថុជាតិ និងបានរួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញបរិវត្តកម្មឌីជីថល សំដៅរួមចំណែកពង្រឹងទំនាក់ទំនងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងទេសចរណ៍ ឱ្យកាន់តែជិតស្និទ្ធមួយកម្រិតទៀតរវាងប្រទេសកម្ពុជា និងប្រទេសចិន ព្រមទាំងប្រទេសជាដៃគូសហការរបស់ Alipay+។

ទំនាក់ទំនង ៖
អង្គភាពទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៩០ ១៩៦
អ៊ីម៉ែល ៖ nbccommunication@nbc.gov.kh
បណ្តាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ៖
www.nbc.gov.kh , www.facebook.com/nationalbankofcambodiaofficial , www.twitter.com/nbccambodia , www.instagram.com/nationalbankofcambodia , www.linkedin.com/company/national-bank-of-cambodia , www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATIA